ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខៈ៦៩៨៥/ប្រ.ក......ប.ស្ថ/៤ខ២/០៨២៥

# ប្រកាស
# ស្តីពី
# គោលការណ៍ណែនាំសម្រាប់ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន
## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក



៦៣៩

- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់
- បានឃើញប្រកាសលេខ ៣៥៦ ប្រ.ក ប.ស្ត ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន
- បានឃើញប្រកាសលេខ ៣៥៩១/០៥២៥ ប្រក ប.ស្ត/វហប ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ ស្តីពីចំណាត់ថ្នាក់គម្រោងអភិវឌ្ឍន៍សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១._**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ សម្រាប់ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន សំដៅលើកកម្ពស់គុណភាពបរិស្ថាន ការពារសុខភាពសាធារណៈ និងរួមចំណែកអភិវឌ្ឍន៍ប្រកបដោយចីរភាពដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តរាល់គម្រោងអភិវឌ្ឍន៍ដែលទទួលបានការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថានពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត។

**ប្រការ៣._**

ម្ចាស់គម្រោងអភិវឌ្ឍន៍ដែលទទួលបានការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថានពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានពីសកម្មភាពគម្រោងក្នុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិ និងដំណាក់កាលបញ្ចប់គម្រោង ដាក់ជូនក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត ដើម្បីពិនិត្យ និងវាយតម្លៃ។

**ប្រការ៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥._**

អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ២កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**អន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



**អ៊ាង សុផល្លែត**

**ឧបសម្ព័ន្ធនៃប្រកាសលេខ ១៩៨៥/ប្រក.បស្ប/ខហប**
**ថ្ងៃ ពុធ ២ កើត ខែ ភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩**
**ត្រូវនឹងថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០២៥**
**ស្តីពីគោលការណ៍ណែនាំក្នុងការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន**
**សម្រាប់គម្រោងអគ្គិសនី**

## ជំពូកទី១៖ សេចក្តីផ្តើម

### ១.១ សេចក្តីផ្តើម

ម្ចាស់គម្រោងត្រូវពណ៌នា៖

❖ **ព័ត៌មានអំពីប្រភព**

<table>
<tr><td>ឈ្មោះទីតាំង</td><td colspan="5">..............................................................................<br>..............................................................................</td></tr>
<tr><td>អាសយដ្ឋានទីតាំង</td><td colspan="5">អគារលេខ.................ផ្លូវលេខ/ឈ្មោះ.....................ភូមិ..................<br>សង្កាត់/ឃុំ.................ខណ្ឌ/ស្រុក.....................រាជធានី/ខេត្ត...............<br>លេខទូរស័ព្ទ...........................E-mail...............................</td></tr>
<tr><td>ប្រភេទផលិតកម្ម</td><td colspan="5">..............................................................................<br>..............................................................................</td></tr>
<tr><td>អ្នកទទួលខុសត្រូវគ្រប់គ្រង</td><td colspan="5">១-តំណាងក្រុមហ៊ុន.....................ជនជាតិ.............សញ្ជាតិ..........<br>លេខទូរស័ព្ទ...........................E-mail...............................<br>២-នាយករដ្ឋបាល.....................ជនជាតិ.............សញ្ជាតិ..........<br>លេខទូរស័ព្ទ...........................E-mail...............................<br>៣-ប្រធានទទួលបន្ទុកបរិស្ថាន.............ជនជាតិ.............សញ្ជាតិ..........<br>លេខទូរស័ព្ទ...........................E-mail...............................</td></tr>
<tr><td>លិខិតអនុញ្ញាតផលិតកម្ម</td><td colspan="5">ចាប់ដំណើរការពី.............................ក្រោមលិខិតអនុញ្ញាត៖<br>១-...................................................................<br>២-...................................................................<br>៣-...................................................................<br>៤-...................................................................<br>៥-...................................................................</td></tr>
<tr><td>ទម្រង់វិនិយោគ</td><td colspan="5">▢ ឯកជនឯកត្តនាមក្នុងស្រុក ▢ ឯកជនពហុនាមក្នុងស្រុក ▢ ឯកជនចម្រុះជាមួយរដ្ឋ<br>▢ ឯកជនឯកត្តនាមក្រៅស្រុក ▢ ឯកជនដៃគូក្នុងស្រុកនិងក្រៅស្រុក ▢ សហគ្រាសរដ្ឋ<br>▢ ឯកជនក្រៅស្រុកចម្រុះជាមួយរដ្ឋ ▢...............................</td></tr>
<tr><td>ចំនួន</td><td>បុគ្គលិកការិយាល័យ</td><td>កម្មករវេន១</td><td>កម្មករវេន២</td><td>កម្មករវេន៣</td><td>ចំនួនសរុប</td></tr>
</table>



៤៤១

| | | | | | |
|---|---|---|---|---|---|
| បុគ្គលិកនិងកម្មករ | | | | | |
| រយៈពេលប្រតិបត្តិការ | ចំនួនម៉ោង/ថ្ងៃ | | ចំនួនថ្ងៃ/អាទិត្យ | | ចំនួនម៉ោងថែម/ថ្ងៃ |
| សមត្ថភាពផលិតកម្ម | ប្រភេទផលិតផល | បរិមាណ/ថ្ងៃ | បរិមាណ/ខែ | បរិមាណ/ត្រីមាស | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

❖ **លក្ខខណ្ឌដែលទីតាំងត្រូវបំពេញក្រោមលិខិតបទដ្ឋានគតិយុត្តបរិស្ថាន**

- ពិពណ៌នាសង្ខេបអំពីប្រវត្តិគម្រោង (ចាប់ផ្តើមដំណើរការគម្រោងមកដល់បច្ចុប្បន្ន)
- បង្ហាញលិខិតបទដ្ឋានគតិយុត្តដែលបានអនុញ្ញាត/ឯកភាពលើគម្រោងដែលមានលក្ខណៈផ្សេងៗគ្នា (វិស័យឧស្សាហកម្ម វិស័យរ៉ែ និងថាមពល វិស័យកសិកម្ម កសិ-ឧស្សាហកម្ម វិស័យធនធានទឹក វិស័យសុខាភិបាល វិស័យទេសចរណ៍ វិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលក្នុងនោះរួមមាន៖

  ១.លិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬកិច្ចសន្យាការពារបរិស្ថាន។

  ២.លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត។

### ១.២ គោលបំណងនៃការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

### ១.៣ វិធីសាស្ត្រនៃការសិក្សា និងរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

- ម្ចាស់គម្រោងត្រូវរៀបរាប់អំពីការកំណត់ទំហំនៃការសិក្សា និងវិធីសាស្ត្រនៃការសិក្សា ដោយផ្អែកទៅលើទិន្នន័យដែលមានស្រាប់ និងទិន្នន័យបឋមលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ដើម្បីធៀបទៅនឹងទិន្នន័យដែលបានបង្ហាញនៅក្នុងរបាយការណ៍អង្កេតតាមដានបរិស្ថាន (EMR) ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬកិច្ចសន្យាការពារបរិស្ថាន
- ម្ចាស់គម្រោងត្រូវបង្ហាញពីឧបករណ៍ និងសម្ភារៈដែលត្រូវប្រើនៅក្នុងពេលសិក្សា។

## ជំពូកទី២៖ ការពិពណ៌នាសកម្មភាពគម្រោង

### ២.១ ទីតាំងគម្រោង

ម្ចាស់គម្រោងត្រូវរៀបរាប់អំពីទីតាំងគម្រោង និងទំហំផ្ទៃដី ដោយបង្ហាញនូវចំណុចនិយាមកា ផែនទីទីតាំងគម្រោង (ផែនទី Topography និងផែនទី Google Map ជាជំនួយ) រួមទាំងប្លង់នៅក្នុងទីតាំងគម្រោងឱ្យបានច្បាស់លាស់។



៤៤២

### ២.២ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត

ម្ចាស់គម្រោងត្រូវរៀបរាប់អំពីលិខិតបទដ្ឋានគតិយុត្ត ដែលទទួលបានពីក្រសួងបរិស្ថានមាន៖

- លិខិតអនុញ្ញាតបញ្ចេញសំណល់រឹង
- លិខិតអនុញ្ញាតបញ្ចេញសំណល់រាវ
- លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់
- លិខិតអនុញ្ញាតបញ្ចេញផ្សែង សំឡេង និងរំញ័រ
- លិខិតបញ្ជាក់គុណភាពខ្យល់ សំឡេង និងរំញ័រ
- ការបង់មូលនិធិទាយជ្ជទានបរិស្ថាន
- ការបង់មូលនិធិបរិស្ថាន និងសង្គម

### ២.៣ សកម្មភាពនៃការអនុវត្តគម្រោង

ម្ចាស់គម្រោងត្រូវរៀបរាប់អំពីសកម្មភាពគម្រោង ដោយបង្ហាញពីដំណាក់កាល (មានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន) ដែលម្ចាស់គម្រោងបាននិងកំពុងអនុវត្តនៅពេលបច្ចុប្បន្ន (ដំណាក់កាលសាងសង់ ឬដំណាក់កាលប្រតិបត្តិគម្រោង ឬដំណាក់កាលបញ្ចប់គម្រោង) រួមមាន៖

- ការប្រើប្រាស់ដី ឬផែនការមេ
- ខ្សែច្រវាក់ផលិតកម្ម ឬដំណើរការអាជីវកម្ម ឬដំណើរការអនុវត្តគម្រោង
- តម្រូវការគ្រឿងចក្រ ឧបករណ៍/សម្ភារៈ វត្ថុធាតុដើម
- ការប្រើប្រាស់កម្លាំងពលកម្ម
- ការប្រើប្រាស់ថាមពល
- ការប្រើប្រាស់ទឹក
- ការគ្រប់គ្រងសំណល់រឹង
- ការគ្រប់គ្រងសំណល់រាវ
- ការគ្រប់គ្រងគុណភាពខ្យល់ សំឡេង និងរំញ័រ
- ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពរបស់បុគ្គលិក-កម្មករ
- ហានិភ័យ។

## ជំពូកទី៣៖ ការអនុវត្តកម្មវិធីអង្កេតតាមដានបរិស្ថាន

នៅក្នុងជំពូកនេះ ម្ចាស់គម្រោងត្រូវរៀបរាប់អំពីកម្មវិធីអង្កេតតាមដានបរិស្ថាន ដែលបានអនុវត្តរយៈពេល ៣ខែ ឬ៦ខែចុងក្រោយ ស្របទៅតាមផែនការគ្រប់គ្រងបរិស្ថាន សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬកិច្ចសន្យាការពារបរិស្ថាន ក្នុងនោះរួមមាន៖

- ការបណ្តុះបណ្តាលដល់បុគ្គលិក-កម្មករ
- ការត្រួតពិនិត្យគុណភាពបរិស្ថាន (ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធានសេដ្ឋកិច្ច-សង្គម) ម្ចាស់គម្រោងត្រូវប្រៀបធៀបទៅនឹងទិន្នន័យដែលមានស្រាប់ដែលមាននៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬកិច្ចសន្យាការពារបរិស្ថាន

- តារាងផ្ទៀងផ្ទាត់ការអនុវត្តកម្មវិធីអង្កេតតាមដានបរិស្ថាន ដែលបានអនុវត្តកន្លងមក ក្នុងនោះរួមមាន៖
    - ការវិភាគគុណភាពដី ឬគុណភាពផេះថ្ម/សំណល់ភក់
    - ការវាស់គុណភាពខ្យល់
    - ការវាស់សំឡេង និងរំញ័រ
    - ការវិភាគគុណភាពសំណល់រាវ/ទឹកកខ្វក់ ដែលបានសម្អាតដោយអាងប្រព្រឹត្តកម្មសំណល់រាវ ឬអាងសិបទិច មុននឹងបញ្ចេញទៅក្នុងប្រភពទឹកសាធារណៈ ឬប្រភពទឹកធម្មជាតិ
    - ការវិភាគគុណភាពទឹកលើដី (ប្រភពទឹកធម្មជាតិ) ទទួលសំណល់រាវដែលបានសម្អាតដោយអាងប្រព្រឹត្តកម្មសំណល់រាវ ឬអាងសិបទិច
    - ការវិភាគគុណភាពទឹកក្រោមដី (ក្នុងករណីមានការពាក់ព័ន្ធនឹងគម្រោង)
- ការចូលរួមផ្តល់យោបល់ពីអ្នកពាក់ព័ន្ធនឹងសកម្មភាពគម្រោង
- ការបង់មូលនិធិបរិស្ថាននិងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន
- ការចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន (បើមាន)
- លទ្ធផលនៃការអនុវត្តកម្មវិធីអង្កេតតាមដានបរិស្ថាន ដែលពាក់ព័ន្ធនឹងហេតុប៉ះពាល់បរិស្ថានសង្គមវិជ្ជមាន និងអវិជ្ជមាន ។

## ជំពូកទី៤៖ សន្និដ្ឋាន និងសំណូមពរ

ម្ចាស់គម្រោងត្រូវធ្វើការសន្និដ្ឋានលើលទ្ធផលនៃការត្រួតពិនិត្យគុណភាពបរិស្ថានជាប្រចាំ ដោយធៀបទៅនឹងទិន្នន័យដែលមានបង្ហាញនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬកិច្ចសន្យាការពារបរិស្ថាន ឬរបាយការណ៍អង្កេតតាមដានបរិស្ថានដែលបានរៀបចំកន្លងមក ដើម្បីបន្តរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានតាមនីតិវិធី និងលើកឡើងនូវសំណូមពរ ដាក់ជូនក្រសួងបរិស្ថាន ដូចមានចែងនៅក្នុងកិច្ចសន្យាការពារបរិស្ថានរបស់ម្ចាស់គម្រោង។

## ឯកសារយោង

## ឧបសម្ព័ន្ធ